# សិក្ខាសាលាថ្នាក់ជាតិ
# ស្ដីពីសេចក្ដីព្រាង "យុទ្ធសាស្ត្រជាតិស្ដីពីបញ្ញាសិប្បនិម្មិត"
# និងការដាក់ឱ្យប្រើប្រាស់ជាផ្លូវការ
# "របាយការណ៍ស្ដីពីការវាយតម្លៃភាពរួចរាល់ផ្នែកបញ្ញាសិប្បនិម្មិតនៅកម្ពុជា"

ថ្ងៃទី១-២ ខែកក្កដា ឆ្នាំ២០២៥

សណ្ឋាគារសុខា រាជធានីភ្នំពេញ

## ១. សាវតារ

ក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភាបានបន្ថែម "បច្ចេកវិទ្យា" ជាអាទិភាពគន្លឹះមួយ លើអាទិភាពគន្លឹះទាំង៤នៃយុទ្ធសាស្ត្រចតុកោណ ព្រមទាំងបានកំណត់បញ្ចកោណទី៥ សម្រាប់ការកសាងសេដ្ឋកិច្ចនិងសង្គមឌីជីថល ដែលសបញ្ជាក់ថារាជរដ្ឋាភិបាលចាត់ទុកបច្ចេកវិទ្យា ជាពិសេសបច្ចេកវិទ្យាឌីជីថល ជាអាទិភាពសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកម្ពុជា។ ក្នុងចំណោមបច្ចេកវិទ្យាឌីជីថលឈានមុខ បញ្ញាសិប្បនិម្មិតជាបច្ចេកវិទ្យាមានភាពលេចធ្លោជាងគេ នាំមកទាំងកាលានុវត្តភាពនិងហានិភ័យ ដែលទាមទារឱ្យមានការគ្រប់គ្រងប្រកបដោយការគិតគូរជាយុទ្ធសាស្ត្រ។ កន្លងមក ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និង គោលនយោបាយរដ្ឋាភិបាលកម្ពុជា ២០២២-២០៣៥ បានកំណត់វិធានការគោលនយោបាយគន្លឹះនិងសកម្មភាពអាទិភាពពាក់ព័ន្ធនឹងបញ្ញាសិប្បនិម្មិតរួចរាល់ ដែលបង្ហាញពីការគិតគូរជាមុនរបស់អ្នករៀបចំគោលនយោបាយ ប៉ុន្តែការរីកសាយ ការវិវឌ្ឍយ៉ាងឆាប់រហ័ស និងភាពងាយស្រួលប្រើប្រាស់របស់បញ្ញាសិប្បនិម្មិតនិយាយជារួម និងបញ្ញាសិប្បនិម្មិតបង្កើតមាតិកា (generative artificial intelligence) និយាយដោយឡែក ទាមទារឱ្យគ្រប់ភាគីពាក់ព័ន្ធលៃលកជាថ្មីឱ្យបានឆាប់រហ័ស ដើម្បីតាមទាន់ស្ថានការណ៍តំបន់និងសកល។

តាំងពីឆមាសទី១ ឆ្នាំ២០២៤ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានស្រាវជ្រាវនិងរៀបរៀងខ្លឹមសារនៃសេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីបញ្ញាសិប្បនិម្មិត។ ក្នុងដំណើរការនេះ ដើម្បីវាយតម្លៃភាពរួចរាល់របស់កម្ពុជាក្នុងការចាប់យកនិងអភិវឌ្ឍបញ្ញាសិប្បនិម្មិតប្រកបដោយសីលធម៌ បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជានិងអង្គការយូណេស្កូ ដោយមានការគាំទ្រពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានចាប់ផ្តើមវាយតម្លៃភាពរួចរាល់ផ្នែកបញ្ញាសិប្បនិម្មិតនៅកម្ពុជាតាំងពីខែវិច្ឆិកា ឆ្នាំ២០២៤មក តាមវិធីសាស្ត្ររបស់អង្គការយូណេស្កូ ដែលមានការទទួលស្គាល់ជាសាកលនិងបានប្រើប្រាស់នៅប្រមាណ៦០ប្រទេសជុំវិញពិភពលោក។ លទ្ធផលសំខាន់ៗនៃការវាយតម្លៃនេះត្រូវបានបញ្ចូលក្នុងសេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីបញ្ញាសិប្បនិម្មិតដែលត្រូវបានអភិវឌ្ឍទន្ទឹមគ្នា និងចេញជាសេចក្តីព្រាងដំបូងនៅខែកុម្ភៈ ឆ្នាំ២០២៥។

តាមរយៈកិច្ចសហការនិងការគាំទ្រពីគណៈកម្មការសេដ្ឋកិច្ចនិងសង្គមប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ (អេស្កាប់) សេចក្តីព្រាងដំបូងត្រូវបានដាក់ពិគ្រោះយោបល់ក្នុងបណ្តាញអ្នកជំនាញក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកអនឡាញចំនួនពីរលើក។ សេចក្តីព្រាងនេះត្រូវបានកែសម្រួលជាបន្តបន្ទាប់ និងឆ្លងកាត់សិក្ខាសាលាពិនិត្យស៊ីជម្រៅនៅរាជធានីភ្នំពេញរយៈពេលពីរថ្ងៃនាដើមខែមេសា និងកិច្ចប្រជុំពិគ្រោះយោបល់ទ្វេភាគីនិងពហុភាគីជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ចំនួន១០លើក។

គិតត្រឹមដំណាច់ខែឧសភា ឆ្នាំ២០២៥ ការវាយតម្លៃផ្នែកបញ្ញាសិប្បនិម្មិតកម្ពុជាបានបញ្ចប់របាយការណ៍ផ្លូវការរួចរាល់ រីឯសេចក្ដីព្រាងយុទ្ធសាស្ត្រជាតិស្ដីពីបញ្ញាសិប្បនិម្មិតត្រូវបានកែសម្រួលចេញជាកំណែទី៤ ដែលមានបញ្ចូលធាតុចូលរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។

## ២. គោលបំណងនៃកម្មវិធី

**សិក្ខាសាលាថ្នាក់ជាតិ**ស្ដីពីសេចក្ដីព្រាងយុទ្ធសាស្ត្រជាតិស្ដីពីបញ្ញាសិប្បនិម្មិតមានគោលបំណង៖

- សម្ពោធនិងផ្សព្វផ្សាយរបាយការណ៍វាយតម្លៃផ្នែកសីលធម៌បញ្ញាសិប្បនិម្មិតនៅកម្ពុជា
- ពិភាក្សានិងផ្ដល់សុពលភាពលើមតិយោបល់ដែលក្រសួង ស្ថាប័នបានផ្ដល់ និងប្រមូលធាតុចូលដែលនៅសេសសល់
- ប្រមូលធាតុចូលពីភាគីពាក់ព័ន្ធផ្សេងៗ រួមមានវិស័យឯកជន គ្រឹះស្ថានអប់រំស្រាវជ្រាវ និងសង្គមស៊ីវិល
- ពិភាក្សាដើម្បីកំណត់ជារួមនូវសកម្មភាពអាទិភាពសំខាន់ៗ សំដៅធ្វើឱ្យយុទ្ធសាស្ត្រជាតិកាន់តែ ល្អប្រសើរ អាចអនុវត្តបាន និងជាឯកសាររួមសម្រាប់កំណត់ទិសដៅជំរុញការចាប់យកនិងអភិបាលកិច្ចបញ្ញាសិប្បនិម្មិតកម្រិតជាតិ
- កៀរគរឱ្យមានការត្រៀមខ្លួនពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីចូលរួមអនុវត្តយុទ្ធសាស្ត្រជាតិនៅពេលដាក់ឱ្យប្រើប្រាស់

## ៣. កាលបរិច្ឆេទ និង ទីតាំង

- **កាលបរិច្ឆេទ៖** ថ្ងៃទី១-២ ខែកក្កដា ឆ្នាំ២០២៥
- **ទីតាំង៖** សណ្ឋាគារសុខាភ្នំពេញ

## ៤. ដៃគូសហការរៀបចំ

- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- គណៈកម្មការសេដ្ឋកិច្ចនិងសង្គមប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ (អេស្កាប់)
- អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ (យូណេស្កូ)

## ៥. អ្នកចូលរួម

- ថ្នាក់ដឹកនាំនិងគ្រប់អង្គភាពពាក់ព័ន្ធនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- តំណាងគ្រប់ក្រសួង ស្ថាប័ន
- តំណាងគណៈកម្មាធិការជាតិអេស្កាប់កម្ពុជានិងតំណាងគណៈកម្មការជាតិយូណេស្កូ
- តំណាងការិយាល័យអ្នកសម្របសម្រួលអង្គការសហប្រជាជាតិនៅកម្ពុជា តំណាងអង្គការយូណេស្កូប្រចាំកម្ពុជា សហប្រធាននៃសម្ព័ន្ធលើបញ្ហាពាក់ព័ន្ធនឹងបរិវត្តកម្មឌីជីថល (Issue-based Coalition on Digital Transformation) អេស្កាប់ យូណេស្កូ សហភាពទូរគមនាគមន៍អន្តរជាតិ និងទីភ្នាក់ងារផ្សេងទៀតនៃអង្គការសហប្រជាជាតិ
- អ្នកជំនាញអន្តរជាតិពាក់ព័ន្ធនឹងបញ្ញាសិប្បនិម្មិត
- តំណាងវិស័យឯកជន គ្រឹះស្ថានអប់រំស្រាវជ្រាវ និងអង្គការសង្គមស៊ីវិល
- តំណាងស្ថានតំណាងបរទេសនៅកម្ពុជានិងដៃគូអភិវឌ្ឍន៍

## ៦. របៀបវារៈ

| ថ្ងៃទី១<br>ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៥ | |
|---|---|
| **ម៉ោង** | **របៀបវារៈ** |
| ១៣:៣០ - ១៤:២៥ | ចុះឈ្មោះអ្នកចូលរួម |
| ១៤:២៥ - ១៤:៣០ | គណៈអធិបតីអញ្ជើញដល់ |
| **សិក្ខាសាលាថ្នាក់ជាតិស្តីពីសេចក្តីព្រាង "យុទ្ធសាស្ត្រជាតិស្តីពីបញ្ញាសិប្បនិម្មិត"** | |
| ១៤:៣០ - ១៥:១០ | • សេចក្តីណែនាំនៃសិក្ខាសាលាថ្នាក់ជាតិស្តីពី "សេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីបញ្ញាសិប្បនិម្មិត" - *១០នាទី*<br>**ឯកឧត្តម ហាក់ សុខហេង**<br>*អនុរដ្ឋលេខាធិការ **ក.ប.ទ.***<br><br>• បទបង្ហាញ "ស្ថានភាពបច្ចុប្បន្ននៃបញ្ញាសិប្បនិម្មិតនៅកម្ពុជា និង អនុសាសន៍ផ្អែកលើការអនុវត្ត UNESCO RAM នៅកម្ពុជា" - *១៥នាទី*<br>**លោក ចាន់ឌី ពិសាល**<br>*ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវគោលនយោបាយឌីជីថល*<br><br>• បទបង្ហាញ "ទិដ្ឋភាពរួមនៃសេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីបញ្ញាសិប្បនិម្មិត" - *១៥នាទី*<br>**ឯកឧត្តម ហាក់ សុខហេង**<br>*អនុរដ្ឋលេខាធិការ **ក.ប.ទ.*** |
| ១៥:១០ - ១៥:៣០ | សម្រាកពិសាអាហារសម្រន់ |
| **សិក្ខាសាលា - ផ្នែកទី១៖ ធាតុផ្សំចាំបាច់នៃការប្រើប្រាស់និងការអភិវឌ្ឍបញ្ញាសិប្បនិម្មិត** | |
| ១៥:៣០ - ១៦:៣០ | • កិច្ចពិភាក្សា "ស្ថានភាពបច្ចុប្បន្ននៃបញ្ញាសិប្បនិម្មិតនៅកម្ពុជា៖ អក្ខរកម្មបញ្ញាសិប្បនិម្មិត ទិន្នន័យ ធនធានកុំព្យូទ័រ និងការប្រើប្រាស់បញ្ញាសិប្បនិម្មិត" - *៦០នាទី*<br>**លោក តាំង ម៉ិនហុង**<br>*ប្រធាននាយកដ្ឋានគោលនយោបាយនិងនីតិកម្ម*<br>*អគ្គលេខាធិការដ្ឋានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល **ក.ប.ទ.***<br>- **ឯកឧត្តមបណ្ឌិត សេង សុភាព** ប្រធានបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា និងជាប្រធានក្រុមប្រឹក្សាសាកលវិទ្យាធិការនៃកម្ពុជា<br>- **ឯកឧត្តម ចាន់ឌី សុធី** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល<br>- **ឯកឧត្តមបណ្ឌិត តាំង ខួនលី** នាយកប្រតិបត្តិមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មីតេជោ<br>- **លោក ធី ទ្រី** នាយកប្រតិបត្តិអង្គការទិន្នន័យអំពីការអភិវឌ្ឍ |

| | |
|---|---|
| | - **លោក ម៉ម សុវត្ថា** សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល<br>- **លោក ហាក់ គឹមសន** នាយកការិយាល័យឌីជីថល ធនាគារអេស៊ីលីដា |
| **កម្មវិធីបើកសិក្ខាសាលាថ្នាក់ជាតិ និង ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការ “របាយការណ៍ស្ដីពីការវាយតម្លៃភាពរួចរាល់ផ្នែកបញ្ញាសិប្បនិម្មិតនៅកម្ពុជា”** | |
| ១៦:៣០ - ១៦:៥៥ | • គណៈអធិបតីអញ្ជើញដល់<br>• គោរពភ្លេងជាតិ<br>• មតិស្វាគមន៍របស់តំណាងអេស្កាប់ - *៥នាទី*<br>**លោកស្រី** Tiziana Bonapace<br>*នាយិកាផ្នែកបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និង ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ នៃអេស្កាប់*<br><br>• មតិស្វាគមន៍របស់តំណាងយូណេស្កូ - *៥នាទី*<br>**លោក** Sardar Umar Alam<br>*តំណាងអង្គការយូណេស្កូប្រចាំប្រទេសកម្ពុជា*<br><br>• សុន្ទរកថាគន្លឹះបើកកម្មវិធី - *១៥នាទី*<br>**ឯកឧត្តម ជា វ៉ាន់ដេត**<br>*រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍* |
| ១៦:៥៥ - ១៧:០៥ | • ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការ «របាយការណ៍ស្ដីពីការវាយតម្លៃភាពរួចរាល់ផ្នែកបញ្ញាសិប្បនិម្មិតនៅកម្ពុជា» និងពិធីប្រគល់របាយការណ៍ជានិម្មិតរូប - *១០នាទី* |
| ១៧:០៥ - ១៧:១៥ | - ថតរូបអនុស្សាវរីយ៍<br>- ចប់សិក្ខាសាលាថ្ងៃទី១ |

| ថ្ងៃទី២<br>ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៥ | |
|---|---|
| **ម៉ោង** | **របៀបវារៈ** |
| ៨:៣០ - ៩:០០ | ចុះឈ្មោះអ្នកចូលរួមថ្ងៃទី២ |
| **សិក្ខាសាលា - ផ្នែកទី២៖ កាលានុវត្តភាព បញ្ហាប្រឈម និងដំណោះស្រាយ ក្នុងការជំរុញការប្រើប្រាស់និងការអភិវឌ្ឍបញ្ញាសិប្បនិម្មិតតាមវិស័យ** | |
| ០៩:០០ - ០៩:២០ | បទបង្ហាញ "អាទិភាពជាយុទ្ធសាស្ត្រ ១-៤" និងការណែនាំអំពីការពិភាក្សាជាក្រុម - *១០នាទី*<br>**លោក តាំង ម៉ុនហុង**<br>ប្រធាននាយកដ្ឋានគោលនយោបាយនិងនីតិកម្ម<br>នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល<br>សំណួរ-ចម្លើយ - *១០នាទី* |
| ៩:២០ - ៩:៣០ | សម្រាកពិសាអាហារសម្រន់ (១០នាទី) |
| ៩:៣០ - ៩:៤០ | **សិក្ខាកាមចូលតាមសាលពិភាក្សា - ១០នាទី**<br>• សាលពិភាក្សាទី១៖ បញ្ញាសិប្បនិម្មិតដើម្បីការអភិវឌ្ឍសេដ្ឋកិច្ច<br>• សាលពិភាក្សាទី២៖ បញ្ញាសិប្បនិម្មិតដើម្បីការអភិវឌ្ឍសង្គម<br>• សាលពិភាក្សាទី៣៖ បញ្ញាសិប្បនិម្មិតដើម្បីរដ្ឋាភិបាលឌីជីថល |
| ៩:៤០ - ១១:០០ | • **កិច្ចពិភាក្សាតាមក្រុមលើប្រធានបទ "កាលានុវត្តភាព បញ្ហាប្រឈម និងដំណោះស្រាយក្នុងការជំរុញការប្រើប្រាស់និងការអភិវឌ្ឍបញ្ញាសិប្បនិម្មិតតាមវិស័យ"**<br>○ កិច្ចពិភាក្សាអំពីបញ្ហាប្រឈមនិងកាលានុវត្តភាព - *២៥នាទី*<br>○ កិច្ចពិភាក្សាអំពីដំណោះស្រាយនិងសំណូមពរ - *២៥នាទី*<br>○ របាយការណ៍និងការបូកសរុបតាមសាលពិភាក្សា - *៣០នាទី* |
| ១១:០០ - ១១:២០ | សម្រាកពិសាអាហារសម្រន់ (២០នាទី) |
| ១១:២០ - ១២:១០ | • **របាយការណ៍នៃលទ្ធផលពិភាក្សាតាមមូលបទ** - *៣០នាទី*<br>• **កិច្ចពិភាក្សារួម** - *២០នាទី*<br>សម្របសម្រួលដោយ **លោកបណ្ឌិត សារិន សុតមង្គល**<br>*នាយកប្រតិបត្តិអង្គការ AI Safety Asia*<br>*និងជាទីប្រឹក្សាទីភ្នាក់ងារជំនាញអង្គការសហប្រជាជាតិ (ESCAP)* |
| ១២:១០ - ១៣:៣០ | **សម្រាកពិសាអាហារថ្ងៃត្រង់** |
| **សិក្ខាសាលា - ផ្នែកទី៣៖ អភិបាលកិច្ចបញ្ញាសិប្បនិម្មិតនៅកម្ពុជា** | |
| ១៣:៣០ - ១៥:០០ | • **បទបង្ហាញ "អភិបាលកិច្ចបញ្ញាសិប្បនិម្មិតនៅកម្ពុជា៖ បច្ចុប្បន្នភាពនិងទិសដៅអនាគត"** - *១៥នាទី*<br>**ឯកឧត្តមបណ្ឌិត សំ សិទ្ធិសេរី** |

| | |
|---|---|
| | *អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន* ***ក.ប.ទ.***<br><br>• **បទបង្ហាញ "ឧត្តមានុវត្តន៍អភិបាលកិច្ចបញ្ញាសិប្បនិម្មិតនៅក្នុងតំបន់"** - *១៥នាទី*<br>**សាស្ត្រាចារ្យ Simon Chesterman**<br>*ព្រឹទ្ធបុរសមហាវិទ្យាល័យច្បាប់នៃសាកលវិទ្យាល័យជាតិសិង្ហបុរី និងជានាយកជាន់ខ្ពស់អភិបាលកិច្ចបញ្ញាសិប្បនិម្មិតនៃកម្មវិធីបញ្ញាសិប្បនិម្មិតសិង្ហបុរី*<br><br>• **ពិភាក្សាជាក្រុម៖ «ហានិភ័យនិងផលប៉ះពាល់នៃបញ្ញាសិប្បនិម្មិតនៅកម្ពុជា»** - *៦០នាទី*<br>**អ្នកសម្របសម្រួល៖ លោកបណ្ឌិត សារិន សុភមង្គល** នាយកប្រតិបត្តិអង្គការ AI Safety Asia និងជាទីប្រឹក្សាទីភ្នាក់ងារជំនាញអង្គការសហប្រជាជាតិ (ESCAP)<br>**វាគ្មិន៖**<br>- **ឯកឧត្តម អ៊ុក គីមសេង** អនុរដ្ឋលេខាធិការ ក្រសួងព័ត៌មាន<br>- **ឯកឧត្តមបណ្ឌិត សំ សិទ្ធិសេរី** អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន<br>- **សាស្ត្រាចារ្យ Simon Chesterman** ព្រឹទ្ធបុរសមហាវិទ្យាល័យច្បាប់នៃសាកលវិទ្យាល័យជាតិសិង្ហបុរី<br>- **លោក Phinith Chanthalangsy** ទីប្រឹក្សាតំបន់ផ្នែកមនុស្សសាស្ត្រនិងសង្គមសាស្ត្រនៃអង្គការយូណេស្កូតំបន់<br>- **លោក ឡេង សិរីវឌ្ឍន៍** អនុប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន ធនាគារជាតិនៃកម្ពុជា<br>- តំណាងក្រុមហ៊ុន Grab (TBD) |
| ១៥:០០ - ១៥:១៥ | សម្រាកពិសាអាហារសម្រន់ |
| ១៥:១៥ - ១៥:៤៥ | **សិក្ខាសាលា** - **ផ្នែកទី៣** (ត)<br>• **កិច្ចពិភាក្សារួម៖ ផ្ដល់សុពលភាពលើអាទិភាពជាយុទ្ធសាស្ត្រ** - *៣០នាទី*<br>ការស្ទង់មតិនិងប្រមូលធាតុចូលបន្ថែម<br>សម្របសម្រួលដោយ **លោកបណ្ឌិត សារិន សុភមង្គល** និង**លោក តាំង ប៊ុនហុង** |
| **សិក្ខាសាលា - ផ្នែកទី៤៖**<br>**កិច្ចសហប្រតិបត្តិការ និង ការជ្រោមជ្រែងការស្រាវជ្រាវ ការអភិវឌ្ឍ និងនវានុវត្តន៍** | |
| ១៥:៤៥ - ១៧:០០ | • **បទបង្ហាញ "គម្រោងសួនឌីជីថល"** – *១៥នាទី*<br>**ឯកឧត្តម ហាក់ សុខហេង**<br>*អនុរដ្ឋលេខាធិការ* ***ក.ប.ទ.***<br><br>• **កិច្ចពិភាក្សាជាក្រុម "កិច្ចសហការនិងការជ្រោមជ្រែងការស្រាវជ្រាវ ការអភិវឌ្ឍ និងនវានុវត្តន៍"** - *៦០នាទី* |

| | |
|---|---|
| | **អ្នកសម្របសម្រួល៖ លោកបណ្ឌិត ហេង តក្កី** ស្ថាបនិកនិងប្រធានមជ្ឈមណ្ឌលមេគង្គសម្រាប់ការពារទិន្នន័យ<br>**វាគ្មិន៖**<br>- **ឯកឧត្តម ហាក់ សុខហេង** អនុរដ្ឋលេខាធិការ **ក.ប.ឧ.**<br>- **លោកបណ្ឌិត ស្រ៊ុន បញ្ញារិទ្ធិ** អគ្គនាយករងនៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (TBD)<br>- **លោក សុខ គីមហេង** អ្នកគ្រប់គ្រងកម្មវិធីអន្តរជាតិវិស្វកម្មសុសវែរ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា<br>- លោក **Joe Hironaka**, ទីប្រឹក្សាប្រចាំតំបន់ផ្នែកទំនាក់ទំនងនិង សារគមនាគមន៍នៃអង្គការយូណេស្កូ<br>- **លោក Jie Lun Ong**, នាយកជាន់ខ្ពស់ផ្នែក Ventures តំបន់អាស៊ីប៉ាស៊ីហ្វិកនៃមជ្ឈមណ្ឌលបច្ចេកវិទ្យា Plug and Play |
| **សិក្ខាសាលា - ផ្នែកទី៥៖**<br>**យន្តការអនុវត្ត តាមដានត្រួតពិនិត្យ និងវាយតម្លៃ** | |
| ១៧:០០ - ១៧:១០ | • **បទបង្ហាញ “យន្តការអនុវត្ត និង ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ”** - *១០នាទី*<br>**លោក តាំង ម៉ិនហុង** |
| **សិក្ខាសាលា - ផ្នែកទី៦៖**<br>**បូកសរុប** | |
| ១៧:១០ - ១៧:២០ | • **មតិយោបល់ផ្សេងៗ**<br>សម្របសម្រួលដោយ **លោកបណ្ឌិត សារិន សុតមង្គល**<br>*នាយកប្រតិបត្តិអង្គការ AI Safety Asia*<br>*និងជាទីប្រឹក្សាទីភ្នាក់ងារជំនាញអង្គការសហប្រជាជាតិ (ESCAP)* |
| ១៧:២០ - ១៧:៣០ | **សុន្ទរកថាបិទ**<br>**ឯកឧត្តម កែវ សុទ្ធិ**<br>*រដ្ឋលេខាធិការ **ក.ប.ឧ.*** |